**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាសម្ពោធព្រះវិហារនៅព្រែកតាទែន**
**ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨**
*ព្រះសហគមន៍ធ្វើជាឪពុកម្ដាយ*

អត្ថបទទី១៖ កណ ១៥,១-៦.២១,១-៣
ដំណឹងល្អ៖ លក ២,២២-៤០

បងប្អូនជាទីស្រឡាញ់!

យើងបានស្ដាប់នៅក្នុងអត្ថបទទីពីរ និងទំនុកតម្កើង យើងបានស្ដាប់ថា **ត្រចៀកកាំនិងចាបបានធ្វើសំបុកនៅជិតអាសនៈ។** ខ្ញុំនឹកឃើញកូនក្មេងដែលនៅទីនេះកំពុងអង្គុយនៅជិតអាសនៈ អង្គុយនៅក្បែររូបសំណាក់ព្រះយេស៊ូ ដែលកំពុងបើកដៃដើម្បីស្វាគមន៍យើង។ នៅពាក់កណ្ដាលរូបព្រះយេស៊ូយើងឃើញបេះដូងពណ៌ក្រហម នេះជាសញ្ញាសំគាល់នៃសេចក្ដីស្រឡាញ់។ នៅថ្ងៃនេះយើងមានកូនក្មេងច្រើន ធ្វើឲ្យខ្ញុំនឹងឃើញដល់សត្វត្រចៀកកាំនិងចាប ដែលធ្វើសំបុកនៅក្បែរអាសនៈ និងឃើញកូនក្មេងដែលកំពុងតែអង្គុយនៅទីនេះនៅក្បែរព្រះយេស៊ូ ដើម្បីទទួលសេចក្ដីស្រឡាញ់ពីព្រះយេស៊ូ។ ដូចយើងបានស្ដាប់នៅក្នុងអត្ថបទទីពីរ **ចូរប្រាថ្នាចង់បានព្រះបន្ទូល ដូចទារកដែលទើបនឹងកើតប្រាថ្នាចង់បានទឹកដោះសុទ្ធពីម្ដាយ។** កូនក្មេងដែលកើតថ្មីៗគេត្រូវការទឹកដោះ ពេលម្ដាយអត់មានទឹកដោះសម្រាប់បំបៅដោះកូន យើងត្រូវទិញម្សៅទឹកដោះគោឲ្យកូន។ ខ្ញុំសង្ឃឹមថា កន្លែងទីនេះដែលមានឈ្មោះព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ ទៅជាកន្លែងមួយយ៉ាងពិសេសដើម្បីទទួលស្វាគមន៍កូនក្មេងទាំងអស់ដែលនៅជុំវិញនេះ ដើម្បីឲ្យគេស្គាល់សេចក្ដីស្រឡាញ់ និងការលើកទឹកចិត្ត ដើម្បីឲ្យគេស្គាល់មេត្តាករុណារបស់ព្រះជាម្ចាស់។ អ្នកដែលជាសរសរទ្រទ្រង់របស់ព្រះសហគមន៍នេះ គឺលោកយាយ រ៉ន និងមីងម្នាក់ទៀត ដែលកំពុងស្វាគមន៍បងប្អូនទាំងអស់។

ដូច្នេះកន្លែងនេះ ដែលជាកន្លែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ឲ្យទៅជាកន្លែងមួយយ៉ាងពិសេស ដើម្បីទទួលស្វាគមន៍កូនៗ។ ពេលខ្ញុំទៅថ្វាយអភិបូជានៅផ្ទះបងស្រីមេត្តាករុណាលើផ្លូវមុនីវង្ស ខ្ញុំឃើញកូនក្មេងប្រហែលជាង២០ ដែលបងស្រីកំពុងចិញ្ចឹមដោយសារឪពុកម្ដាយបានបោះបង់ចោលហើយបងស្រីរើសយកមកចិញ្ចឹម។ ឪពុកម្ដាយដែលបានបង្កើតកូនក្មេងទាំងនោះហើយ គ្មានសមត្ថភាពដើម្បីចិញ្ចឹមហើយទុកចោល។ នៅក្នុងចំណោមកូនទាំងនោះមានកូនក្មេងពីរនាក់ដែលឪពុកម្ដាយបានលក់ឲ្យគេ យើង

មានរឿងដូចនេះយ៉ាងច្រើនដែលឪពុកម្តាយខ្វះខាតហើយយកកូនទៅលក់។ ដូច្នេះថ្ងៃនេះជាឱកាសមួយ ដើម្បីភ្ញាក់ស្មារតី យើងជាព្រះសហាគមន៍កាតូលិក យើងជាគ្រីស្តបរិស័ទ យើងជាពុទ្ធបរិស័ទ យើងជាឪពុកម្តាយឲ្យយើងយល់ថាយើងមានតួនាទីផ្តល់ភាពកក់ក្តៅសេចក្តីស្រឡាញ់ដល់កូនៗរបស់ខ្លួន។

ថ្ងៃនេះខ្ញុំអញ្ជើញព្រះសហាគមន៍របស់យើងទាំងអស់ ជាពិសេសនៅកន្លែងនេះជាកន្លែងនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ ធ្វើដូចម្តេចឲ្យព្រះសហាគមន៍ទៅជាឪពុកទៅជាម្តាយ សម្រាប់កូនៗមួយចំនួនដែលមិនបានស្គាល់សេចក្តីស្រឡាញ់ពីឪពុកម្តាយ។ យើងដឹងថា នៅជុំវិញយើងមានកូនក្មេងមួយចំនួនធំ ដោយសារជីវភាពខ្វះខាតឪពុកម្តាយបានទៅធ្វើការងារនៅប្រទេសថៃ និងប្រទេសនានាហើយចោលកូនៗទុកនៅជាមួយលោកយាយលោកតា នៅពេលនោះគេខ្វះសេចក្តីស្រឡាញ់ ការថ្នាក់ថ្នមពីឪពុកម្តាយដែលជួយមើល អប់រំណែនាំ។ ខ្ញុំជឿថាកន្លែងនេះ ដែលយើងបានចាប់ផ្តើមជាមួយកាយរិទ្ធិប៉ុន្មានឆ្នាំហើយ ដើម្បីប្រមូលកូនក្មេងប៉ុន្តែប្រាប់អ្នកភូមិកុំព្រួយបារម្ភថាយើងចាប់កូនគាត់ឲ្យចូលសាសនាទេ គឺដើម្បីអប់រំ ដើម្បីណែនាំ ដើម្បីឲ្យស្គាល់តម្លៃនៃជីវិត ដើម្បីឲ្យចេះជួយគ្នាទៅវិញទៅមក ដើម្បីឲ្យគេចេះគោរពលោកតាលោកយាយ ឪពុកម្តាយ បងប្អូន នេះជាកម្មវិធីរបស់កាយរិទ្ធិ ដើម្បីឲ្យកូនក្មេងទទួលអំណរសប្បាយក្នុងមួយអាទិត្យម្តង។ ខ្ញុំសង្ឃឹមថាលោកបូជាចារ្យដែលនៅទីនេះ ធ្វើដូចម្តេចដើម្បីឲ្យកន្លែងនេះទៅជាកន្លែងអប់រំ អប់រំកូនក្មេងតាមរយៈកម្មវិធីកាយរិទ្ធិ បន្តិចទៀតយើងបង្កើតសាលាមត្តេយ្យ ដែលណែនាំឲ្យកូនតូចៗទទួលចំណេះដឹង ទទួលការយកចិត្តទុកដាក់ ទទួលអំពីបញ្ហានៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីរៀបចំអនាគត។ ជាពិសេសនៅក្នុងឆ្នាំគ្រួសារ ដូចរូបក្នុងផ្ទាំងប៉ាណូនេះ យើងឃើញលោកតាលោកយាយសប្បាយចិត្តនៅពេលកូនៗនាំចៅមកលេង យើងអាចបង្កើតគ្រួសារដ៏សុខសាន្តនៅពេលយើងចេះស្រឡាញ់គ្នាទៅវិញទៅមក នៅពេលយើងចេះគោរពគ្នាទៅវិញទៅមក នៅពេលយើងទុកកូនរបស់យើងមានតម្លៃដល់កំពូល។ ដូច្នេះព្រះសហាគមន៍របស់យើងនៅទីនេះ ត្រូវទៅជាកន្លែងមួយដែលត្រូវសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង។ ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលយើងឃើញនៅក្នុងគម្ពីរដំណឹងល្អ **ព្រះយេស៊ូដែលទទួលស្វាគមន៍កូនក្មេង**ដោយសារនៅក្នុងសម័យនោះ កូនក្មេងគេមិនសូវឲ្យតម្លៃនិងគេខ្លាចកូនក្មេងទាំងនោះរំខានព្រះយេស៊ូ គេក៏បណ្តេញកូនក្មេងទាំង

នោះ ប៉ុន្តែផ្ទុយទៅវិញព្រះយេស៊ូមានព្រះបន្ទូលថា កុំបណ្ដេញកូនក្មេងទាំងនេះសូមឲ្យគេមកទីនេះ និងព្រះយេស៊ូប្រទានពរ និងថើបកូនក្មេងទាំងនោះ និងប្រៀនប្រដៅដល់មនុស្សពេញវ័យឲ្យប្រយ័ត្ន **បើចង់ចូលស្ថានបរមសុខសូមមានចិត្តគំនិតដូចកូនក្មេង** បើចង់មានជីវិតអស់កល្បជានិច្ចសូមកែប្រែចិត្តគំនិត ដើម្បីមានចិត្តដូចកូនក្មេងមានន័យថា បន្ទាប់ពីទារកប្រសូត ជាឪពុកម្ដាយដែលត្រូវចិញ្ចឹមគាត់ ជាឪពុកម្ដាយដែលត្រូវថែរក្សាគាត់ ជាឪពុកម្ដាយដែលប្រគល់ជីវិតឲ្យគាត់។ ឪពុកម្ដាយត្រូវមានការទទួលខុសត្រូវយ៉ាងខ្ពស់ ដើម្បីចិញ្ចឹម ដើម្បីថែរក្សា ដើម្បីអប់រំកូន។ សម្រាប់យើងជាមនុស្សពេញវ័យក៏ដូចគ្នាដែរ យើងធ្វើដូចម្ដេចដើម្បីទីពឹងលើឧបការគុណរបស់ព្រះជាម្ចាស់ ធ្វើដូចម្ដេចដើម្បីឲ្យព្រះជាម្ចាស់ប្រទានជីវិតឲ្យយើង។ **ទឹកដោះដែលយើងត្រូវការគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់** ការថែរក្សាដែលយើងត្រូវការដើម្បីទៅមុខគឺសេចក្ដីស្រឡាញ់ដែលមកពីព្រះបិតាផ្ទាល់។

ដូច្នេះ នៅពេលយើងមានចិត្តគំនិតដូចកូនក្មេង ដោយទីពឹងលើព្រះបិតា ដោយមានចិត្តគំនិតដូចកូនក្មេង ដែលចេះមើលអ្វីៗទាំងអស់ដែលនៅជុំវិញដោយពោរពេញដោយអំណរសប្បាយគឺណែនាំឲ្យយើងរកឃើញផ្លូវនៃជីវិតដើម្បីទទួលការសង្គ្រោះ មានន័យថា ដើម្បីទទួលជីវិតលើផែនដីនេះ និងជីវិតដ៏សុខសាន្តនៅស្ថានបរមសុខគឺជីវិតរួមជាមួយព្រះជាម្ចាស់។ ថ្ងៃនេះខ្ញុំអធិដ្ឋាន ដើម្បីឲ្យកន្លែងនេះទៅជាកន្លែងមួយដើម្បីអប់រំណែណនាំកូនក្មេង បង្ហាញសេចក្ដីស្រឡាញ់និងលើកទឹកចិត្តថ្នាក់ថ្នមកូនក្មេង ដើម្បីឲ្យគេមានអនាគតដ៏ល្អ។ សព្វថ្ងៃមានកូនក្មេងជាច្រើន ដែលកើតមកហើយគ្មានយុត្តិធម៌ គ្មានសំណាងដូចកូនក្មេងដទៃ ដោយសារឪពុកម្ដាយមានជីវភាពក្រីក្រ។ យើងជាឪពុកម្ដាយ យើងជាលោកតាលោកយាយ អាទិភាពទីមួយគឺចិញ្ចឹម ថែរក្សា អប់រំណែនាំកូន សម្រាប់ព្រះសហគមន៍កាតូលិក នៅក្នុងឆ្នាំគ្រួសារ អាទិភាពទីមួយគឺធ្វើជាឪពុកម្ដាយសម្រាប់កូនក្មេងដែលគ្មានទីពឹង ដើម្បីបង្ហាញអំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង និងរបៀបដែលព្រះជាម្ចាស់ណែនាំឲ្យយើងរីកចម្រើននៅក្នុងជីវិត។

ចាប និងត្រចៀកកាំបានធ្វើសំបុកនៅក្បែរអាសនៈ កូនក្មេងទាំងអស់ចង់ធ្វើសំបុកនៅក្បែរព្រះយេស៊ូដើម្បីទទួលសេចក្ដីស្រឡាញ់ ដើម្បីទទួលកម្លាំងកាយកម្លាំងចិត្ត។ ព្រះសហគមន៍ធ្វើជាឪពុកម្ដាយសម្រាប់កូនទាំងឡាយ។ អាម៉ែន៕